**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧០៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលផ្ទៃដីក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍វិស័យទេសចរណ៍ធម្មជាតិ ក្នុងឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ "គីរីរម្យ" ខេត្តកំពង់ស្ពឺ របស់ក្រុមហ៊ុនគីរីរម្យ អេកូធួរីសឹម អ៊ីនវេសមេន និងគម្រោងវិនិយោគអភិវឌ្ឍន៍ដំណាំកៅស៊ូ ដាំដំណាំ កសិ-ឧស្សាហកម្ម និងដំណាំកសិកម្ម ក្នុងតំបន់ដែនជម្រកសត្វព្រៃស្នួល ខេត្តក្រចេះ របស់ក្រុមហ៊ុន ធីធីវ៉ាយ អភិវឌ្ឍន៍ដំណាំកសិកម្ម ខូអិលធីឌី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន

- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធី នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- យោងសេចក្តីសម្រេចលេខ ១២៥ សសរ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច
- យោងលិខិតលេខ ១៤៧១ សជណ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

## សម្រេច

**មាត្រា ១.-**

ត្រូវបានកែសម្រួលផ្ទៃដីពីទំហំ **៦០៩ (ប្រាំមួយរយប្រាំបួន) ហិកតា** ដែលមានចែងក្នុងអនុក្រឹត្យលេខ **១៧៣ អនុក្រ.បក** ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៩ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និងអនុក្រឹត្យលេខ **០៨ អនក្រ.បក** ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១០ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៦០៩ (ប្រាំមួយរយប្រាំបួន) ហិកតា** ក្នុងតំបន់ឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ **"គីរីរម្យ"** ក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ

មកជាផ្ទៃដីទំហំ **២០ (ម្ភៃ) ហិកតា** សម្រាប់ផ្តល់ជូនក្រុមហ៊ុន **គីរីរម្យ អេកូទូរីសឹម អ៊ីនវេសមេន** ធ្វើការវិនិយោគអភិវឌ្ឍន៍វិស័យទេសចរណ៍ធម្មជាតិ។

**មាត្រា ២.-**

ត្រូវបានកែសម្រួលផ្ទៃដីពីទំហំ **៩.៧៨០ (ប្រាំបួនពាន់ប្រាំពីររយប៉ែតសិប) ហិកតា** ដែលមានចែងក្នុងអនុក្រឹត្យលេខ **១៧៣ អនក្រ.បក** ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៩ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និងអនុក្រឹត្យលេខ **១២៥ អនក្រ.បក** ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១០ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៩.៧៨០ (ប្រាំបួនពាន់ប្រាំពីររយប៉ែតសិប) ហិកតា** ស្ថិតក្នុងតំបន់ដែនជម្រកសត្វព្រៃស្នួល ឃុំពីរធ្នូ ស្រុកស្នួល ខេត្តក្រចេះ មកជាផ្ទៃដីទំហំ **២១៥ (ពីររយដប់ប្រាំ) ហិកតា** សម្រាប់ផ្តល់ជូនក្រុមហ៊ុន **ធីធីវ៉ាយ អភិវឌ្ឍន៍ដំណាំកសិកម្ម ខូអិលធីឌី** ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍ដំណាំកៅស៊ូ ដាំដំណាំកសិ-ឧស្សាហកម្ម និងដំណាំកសិកម្ម។

**មាត្រា ៣.-**

ផ្ទៃដីទំហំ **៥៨៩ (ប្រាំរយប៉ែតសិបប្រាំបួន) ហិកតា** ដែលនៅសល់ពីការកែសម្រួលផ្តល់ជូនក្រុមហ៊ុន **គីរីរម្យ អេកូទូរីសឹម អ៊ីនវេសមេន** ដូចមានចែងក្នុង **មាត្រា ១** ត្រូវដាក់បញ្ចូលជាដីឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ **"គីរីរម្យ"** ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន។

ផ្ទៃដីទំហំ **៩.៥៦៥ (ប្រាំបួនពាន់ប្រាំរយហុកសិបប្រាំ) ហិកតា** ដែលនៅសល់ពីការកែសម្រួលផ្តល់ជូនក្រុមហ៊ុន **ធីធីវ៉ាយ អភិវឌ្ឍន៍ដំណាំកសិកម្ម ខូអិលធីឌី** ដូចមានចែងក្នុង **មាត្រា ២** ត្រូវដាក់បញ្ចូលជាដីតំបន់ដែនជម្រកសត្វព្រៃស្នួលក្នុងភូមិសាស្ត្រខេត្តក្រចេះ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន។

**មាត្រា ៤.-**

ចំពោះទីតាំងដីដែលបានកែសម្រួល ដូចមានចែងក្នុង **មាត្រា ១** និង **មាត្រា ២** ក្រសួងបរិស្ថានត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ក្នុងការរៀបចំផែនទីកំណត់ទីតាំង ដែលមាននិយាមកាច្បាស់លាស់ ដោយមិនឱ្យប៉ះពាល់ដីអាស្រ័យផលរបស់ប្រជាពលរដ្ឋ។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលខេត្តកំពង់ស្ពឺ និងខេត្តក្រចេះ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ